## ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបលោកសាស្ត្រាចារ្យនៃមជ្ឈមណ្ឌល សម្រាប់ការស្រាវជ្រាវតំបន់អាស៊ីបូព៌ា នៅសកលវិទ្យាល័យអន្តរជាតិ **Akita** នៃប្រទេសជប៉ុន



នៅរសៀលថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និង សិប្បកម្ម បានទទួលជួប លោក **Katsuhiko Umehara** អតីតតំណាងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកិច្ចសហប្រតិបត្តិការឧស្សាហកម្ម និងសេដ្ឋកិច្ចនៃកិច្ចប្រជុំរវាងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន (AMEICC) និងជាអតីតប្រធានកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច និងបច្ចុប្បន្នជា សាស្ត្រាចារ្យនៃមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវតំបន់អាស៊ីបូព៌ា (CEAR) នៅសកលវិទ្យាល័យអន្តរជាតិ Akita នៃប្រទេសជប៉ុន និងសហការី ដើម្បីសំដែងការគួរសមនិងពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Katsuhiko Umehara** បានសម្ដែងទឹកចិត្តរីករាយចំពោះការមកបំពេញទស្សនៈកិច្ចនៅកម្ពុជា និងវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា ។ លោក **Katsuhiko Umehara** បានបញ្ជាក់ថា: លោកធ្លាប់មក កម្ពុជា ប្រមាណ៦ ទៅ ៧ ដង មកហើយ ចាប់តាំងពីឆ្នាំ ១៩៩៦ ដែលជាដំណើរទស្សនៈកិច្ចលើកទី១ ទៅកាន់ខេត្តកោះកុង ដើម្បីស្រាវជ្រាវពីសក្ដានុពលសេដ្ឋកិច្ចទីនោះ។ ក្នុងដំណើរទស្សនៈកិច្ចលើកនេះ លោក និងសហការីក៏បានទៅទស្សនកិច្ច នៅ ខេត្តកោះកុង និងក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលមានក្រុមហ៊ុនរោងចក្រជប៉ុន និងក្រុមហ៊ុនដ៏ទៃទៀតកំពុងដំណើរការ អាជីវកម្មរបស់ខ្លួនប្រកបដោយសក្ដានុពល។ លោក **Katsuhiko Umehara** បានជម្រាបថា: មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវតំបន់អាស៊ីបូព៌ា នៃសាកលវិទ្យាល័យអន្តរជាតិ Akita ប្រទេសជប៉ុន ត្រូវបានបើកដំណើរការនៅខែមករា ឆ្នាំ ២០១២ ។ មជ្ឈមណ្ឌល គឺជាស្ពានរវាងទីក្រុង Akita និងតំបន់អាស៊ីបូព៌ា ក្នុងទំនាក់ទំនង និងនាំផលប្រយោជន៍ទៅវិញ ទៅមកផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ។ ដោយឡែកសាស្ត្រាចារ្យក្នុងមជ្ឈមណ្ឌល សម្រាប់ការស្រាវជ្រាវតំបន់អាស៊ីបូព៌ា (CEAR) បានទទួលភារកិច្ចចូលរួម និងធ្វើទស្សនកិច្ចផ្នែកធុរៈកិច្ច ដើម្បីអភិវឌ្ឍន៍ទីផ្សារ និងជម្រុញការវិនិយោគនៅតំបន់ អាស៊ីបូព៌ា តាមតម្រូវការ ។ ក្នុងដំណើរទស្សនៈកិច្ចនេះ លោកបានដឹកនាំ លោក **Toshiyuki Watanabe** ជានិស្សិត បញ្ចប់ការសិក្សានៅមជ្ឈមណ្ឌល CEAR ទទួលបន្ទុកជាអ្នកស្រាវជ្រាវ ដើម្បីពិនិត្យលទ្ធភាពមើលពីការកសាងមជ្ឈមណ្ឌលសុខមាលមនុស្សចាស់នៅកម្ពុជា ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្ដែងការស្វាគមន៍ និងមានទឹកចិត្តរីករាយចំពោះការជួបលោក **Katsuhiko Umehara** ជាថ្មីម្ដងទៀត ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បាននំរំលឹកឡើងវិញពីអនុស្សាវរីយ៍ និងការបំពេញកិច្ចការជាមួយគ្នា ទាក់ទងនិងការងារពាណិជ្ជកម្មអន្តរជាតិ ក៏ដូចជាកិច្ចចរចារបង្កើតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី រវាងអាស៊ាន–ជប៉ុន ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណដល់លោក **Katsuhiko Umehara** ដែលបានជួយរៀបចំចាត់ចែង ឱ្យនិស្សិតកម្ពុជាបានចូលសិក្សានៅសាកលវិទ្យាល័យមួយ នៅទីក្រុង Sendai ទាក់ទង និងបច្ចេកវិទ្យា ណាណូ(Nano Technology) ។

ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីសក្តានុពល និងស្ថានភាពអំណោយផលនៃ ប្រទេសកម្ពុជា ដែលមានកត្តា ០៤យ៉ាងជាសំខាន់ គឺៈកត្តាសន្តិភាព–ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច–ក្របខ័ណ្ឌច្បាប់មានតម្លាភាព និងអាចប៉ាន់ប្រមាណបាន– និងភាពអនុគ្រោះពាណិជ្ជកម្មដែលកម្ពុជាទទួលបានពីប្រទេសអភិវឌ្ឍន៍ និង ប្រទេស

ជាដៃគូ ។ ទាក់ទងវិស័យឧស្សាហកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកឡើងពីគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ដែលផ្តោតការយកចិត្តទុដាក់លើការធ្វើពិពិធកម្មឧស្សាហកម្ម និងបង្កើតតម្លៃបន្ថែមខ្ពស់ ហើយជាប្រវត្តិសាស្ត្រផងដែរ ដែលវិស័យឧស្សាហកម្មកម្ពុជា កាលពីឆ្នាំ២០១៣នេះ ទទួលបានកំណើនផលិតផលសរុបក្នុងស្រុក(GDP) ចំនួនជាង ២៨% លើសវិស័យកសិកម្មដែលធ្លាប់ជាវិស័យឈានមុខ ។

ផ្អែកតាមសក្តានុពល និងស្ថានភាពអំណោយផលរបស់កម្ពុជា ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអំពាវនាវឱ្យវិនិយោគិនជប៉ុនមកបណ្តាក់ទុន នៅកម្ពុជាឱ្យបានច្រើនថែមទៀត ជាពិសេសឧស្សាហកម្មគាំទ្រដល់សហគ្រាសខ្នាតតូច និងមធ្យម (SME) នៅកម្ពុជា ។ ទាក់ទងនិងការបង្កើតមជ្ឈមណ្ឌល សុខមាលមនុស្សចាស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរ និងលើកទឹកចិត្តឱ្យពិនិត្យលទ្ធភាពនៅតំបន់មាត់សមុទ្ររបស់កម្ពុជា ដែលមានខ្យល់អាកាសបរិសុទ្ធ និងទេសភាពល្អត្រកាល ដូចជា : ខេត្តកោះកុង–កំពង់សោម–កំពត និង ខេត្តកែប ជាដើម ។